ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៤៤៤

លេខៈ ១៨៧

ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០០ **គានាមប្រជារាស្ត្រខ្មែរ**

<u>**សាលដីកា**</u> **តុលាការកំពូល**

លេខៈ ៣១៣ បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៥

ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២-លោក រឿល មួន ជាចៅក្រម

៣-លោក ឈឹម ស៊ីផល ជាចៅក្រម

៤-លោក សោម សិរីវឌ្ឍ ជាចៅក្រមរបាយការណ៍

៥-លោក ម៉ុង មុនីចរិយា ជាចៅក្រម

ក្រឡាបញ្ជី

លោក **អ៊ី សុផុន**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៣២"ង" ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧៣៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **សុខ ស្រេង** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីភូមិបាលស្រុក ទីលំនៅសព្វថ្ងៃភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ផ្ទេរសិទ្ធិឱ្យឈ្មោះ ប្រាក់ ប៉ូលី ។

មេធាវីលោក សួង ចាន់ថន ។

ចុងចម្លើយឈ្មោះ**នូរ ស្រេង** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ចុងចម្លើយឈ្មោះ**សរ ឌុល** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ចុងចម្លើយឈ្មោះ**អ៊ូច ស្រេង**(ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ចុងចម្លើយឈ្មោះ**សុខ វី** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ចុងចម្លើយឈ្មោះ**សយ សៀងចាត់** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

ចុងចម្លើយឈ្មោះ **អៃ ហំ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

លោក អៃ ហំ តំណាងឱ្យប្រជាជន ៦គ្រួសារ ។

លោកមេធាវី នូ ចន្ថា ។

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំគ្រប់គ្រងដីល្វែងលេខ ១២៨ ,១២៩

បានឃើញបណ្តឹងសាទុក្ខលេខ១០១ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់ឈ្មោះ អៃ ហំ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣២"ង" ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៨៧ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១០-០៣-១៩៩៩ របស់ដើមចោទឈ្មោះប្រាក់ ប៉ូលី បានឆ្លើយថា ខ្លួនប្តឹងសុំសិទ្ធិគ្រប់គ្រងដីល្វែងលេខ ១២៨,១២៩ និងឱ្យរុះរើផ្ទះចេញ ។ ដោយហេតុថា ឈ្មោះ អ៊ូរ ស្រេង, សុខ វី,សរ ឌុល បានសង់ផ្ទះចូលមកលើដីល្វែងទាំងនេះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៧០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១០-៣-១៩៩៩ របស់ដើមចោទឈ្មោះប្រាក់ ប៉ូលី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ប្រគល់ដីលំនៅដ្ឋានឡូត៍ល្វែងលេខ១២៨,១២៩ ដែលមានប័ណ្ណកម្មសិទ្ធិលេខ រស ៨.០៣០០ ស្ថិតនៅភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ជាកម្មសិទ្ធិផ្តាច់មុខ ដល់ឈ្មោះប្រាក់ ប៉ូលី ដែលជាតំណាងឱ្យឈ្មោះសុះ ស្រេន និងលឹម ទីនាស់ ជាឪពុកម្តាយក្មេក បន្ទាប់ពីសាលក្រមនេះមានអានុភាពអនុវត្ត ។

៣-ឱ្យភាគីចុងចំលើយទាំងអស់ ព្រមទាំងជនទាំងឡាយដែលបានសង់លំនៅដ្ឋានរំលោភចូលក្នុងដីល្វែងលេខ ១២៨,១២៩ ដែលមានប័ណ្ណសំគាល់សិទ្ធិលេខ រស ០៣០០ នោះរុះរើលំនៅដ្ឋានរបស់ខ្លួនចេញដោយគ្មានលក្ខខ័ណ្ឌបន្ទាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។

៤-ឱ្យឈ្មោះប្រាក់ ប៉ូលី ជាដើមចោទជួយឧបត្ថម្ភដល់ចុងចំលើយឈ្មោះអ៊ួចស្រេងនូវប្រាក់ចំនួន ១០.០០០បាត (មួយម៉ឺនបាត) ដើម្បីរុះរើ និងរកទីតាំងលំនៅដ្ឋានថ្មី ។

៥-ឱ្យចុងចំលើយទាំងអស់រួមគ្នាបង់ប្រាក់ប្រដាប់ក្ដីចំនួន៧០០០រ ដែលដើមចោទបានបង់ទុកហើយនេះ សងទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រក្នុងអត្រាមួយភាគរយលើទឹកប្រាក់ថ្លៃដីពីរល្វែងស្មើ ១៦០.០០០បាត(មួយរយហុកសិបពាន់បាត) ក្នុងចំនួនប្រាក់គិតពន្ធនេះ ប្រាក់ចំនួន ៨០% បង់ចូលថវិការដ្ឋ និង ២០% បង់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូភាគី ទុកសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពីរខែ គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៨៥ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ របស់ឈ្មោះអ៊ួរស្រេង ,ស ឌុល,សុខ វី,អៃ ហំ ម៉ុត បារាំង,សយ សៀងហាក់ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៧០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩របស់តុលាការខេត្តបន្ទាយមានជ័យ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៧"គ" ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៨-០៨-១៩៩៩របស់ដើមបណ្ដឹងឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ៧០ ចុះថ្ងៃទី ២៩-០៦-១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រ ប្រាក់នេះបានចំណាយលើពន្ធចុះបញ្ជីក្ដី និងពន្ធភ្លើង២៥៥០រ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០រ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០រ សរុប ១៣.០០០រ ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងបណ្ដឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្ដឹងឧទ្ធរណ៍ ។ បើកផ្លូវប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះ អៃ ហំ (អ្នកតំណាង) ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៧"គ" ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣២"ង"ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី២៨-០១-២០០០ របស់ឈ្មោះអ៊ៃ ហំ (អ្នកតំណាង) ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ០៧"គ" ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៣-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១០១ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់ឈ្មោះ អ៊ៃ ហំ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣២"ង" ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០០ របស់ឈ្មោះអ៊ៃ ហំ ។

បានឃើញសារណាតប ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះប្រាក់ ប៊ុលី ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះជាវិវាទប្តឹងទាមទារដីសុំក្រុមប្រឹក្សាជំនុំជំរះសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះអ៊ៃ ហំ នាពេលសវនាការថា : ដីទំនាស់នេះ បងប្អូនខ្លួនទាំង៦គ្រួសារបានចូលមកកាប់គាស់រានព្រៃរស់នៅតាំងពីឆ្នាំ១៩៩១មក ដំបូងដីទំនាស់នេះសុទ្ធតែជាព្រៃ ដោយមិនដឹងថាដីនេះបែរមុខទៅខាងណាទេ ។ ហើយពេលនោះក៏គ្មានអ្នកណាកាន់កាប់ដែរ ទើបតែនៅឆ្នាំ១៩៩៩ ពេលដីឡើងថ្លៃ ស្រាប់តែឈ្មោះប្រាក់ ប៊ុលី មកប្តឹងទាមទារ ខ្លួនសុំសំណូមពរឱ្យឯកឧត្តមប្រធានក្រុមប្រឹក្សាជំនុំជំរះសំរេចបង្វិលរឿងនេះទៅសាលាឧទ្ធរណ៍សំរេចឡើងវិញជាថ្មី

បានស្តាប់ចំលើយរបស់ឈ្មោះប្រាក់ ប៊ុលី នាពេលសវនាការថា : ខ្លួនសុំឱ្យចុងចំលើយរុះរើផ្ទះចេញពីដី ដីនេះឪពុកក្មេកខ្លួនទិញពីលោក ប៉ោ វណ្ណៈ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកនូ ចន្ថា ជាមេធាវីការពារឱ្យចុងចំលើយ បានលើកឡើងថា : ដីទំនាស់នេះ កូនក្តីខ្លួនបានធ្វើការកាប់ឆ្ការព្រៃរស់នៅតាំងពីឆ្នាំ១៩៩១ មក ហើយម្យ៉ាងទៀតតំបន់នេះជាកន្លែងអសន្តិសុខ ពុំមានអ្នកណាហ៊ានរស់នៅទេ ។

ដូចនេះក្នុងនាមខ្លួនជាមេធាវីការពារឱ្យចុងចំលើយ ខ្លួនសុំឱ្យក្រុមប្រឹក្សាជំនុំជំរះសំរេចបដិសេធដីកាសាលាឧទ្ធរណ៍ចោល និងបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍សំរេចឡើងវិញ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចំលើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់លោកអែ ហ៊ំ តំណាងឱ្យភាគីចុងចំលើយ ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើកយកមកជំនុំជំរះបានតាមបញ្ញត្តិមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា នាសវនាការនៅតុលាការខេត្តបន្ទាយមានជ័យ ភាគីចុងចំលើយសុទ្ធតែបានឆ្លើយទទួលស្គាល់ថាដើមឡើយពួកខ្លួនរួមទាំងដើមចោទផងដែរ បានរួមគ្នាទិញដីឡូត៍លេខ១៣០ ហើយធ្វើការបែងចែកជា៩ចំណែក ក្នុងម្នាក់ៗបាន ៤ម x ៤ម ហើយនៅពេលសាងសង់លំនៅដ្ឋានបានធ្វើចូលទៅលើដីឡូត៍លេខ ១២៨,១២៩ ផ្នែកខាងក្រោយនៃលំនៅដ្ឋានរបស់ខ្លួនទៀត ដោយអាងហេតុថាដីខាងក្រោយគ្មានអ្នកណាគ្រប់គ្រង ។

- យល់ឃើញថា ដីឡូត៍លេខ១២៨,១២៩ ត្រូវបានលោកប៉ោ វណ្ណៈ គ្រប់គ្រងជាកម្មសិទ្ធិរបស់ខ្លួនតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ ហើយក្រោយមកបានលក់ឱ្យដើមចោទនៅក្នុងឆ្នាំ១៩៩៩ ដូចនេះការរបស់ភាគីចុងចំលើយដែលបានធ្វើលយចូលទៅលើដីឡូត៍នេះ គឺបានបំពានលើអចលនទ្រព្យរបស់អ្នកដទៃហើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣២"ង" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

## ហេតុដូចនេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់លោកអែ ហ៊ំ តំណាងឱ្យភាគីចុងចំលើយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៣២"ង"ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក ប្រាក់ ប៉ូលី បានបង់នៅតុលាការកំពូលចំនួន ១៩០០០៛ គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨៦០៛ សំរាប់

ជាររង្វាន់ក្រឡាបញ្ជីការន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛

តំរូវឱ្យលោកអៃ ហំ សងប្រាក់ចំនួន ១៩.០០០៛នេះ ទៅឱ្យឈ្មោះប្រាក់ ប៉ូលី និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រចំនួន១%តាមការកំណត់របស់តុលាការថ្នាក់ក្រោម ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ។